**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ០៦៣/១៩ **ក.ប/ស.ជ.ណ.ខ.ល**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មី ចាប់ពីឆ្នាំ២០១៩តទៅ សម្រាប់សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង

បន្ទាប់ពីក្រសួងបានចេញសេចក្តីណែនាំលេខ០៥៧/១៩ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងសេចក្តីណែនាំលេខ០៥៨/១៩ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩ ក្រសួងសង្កេតឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតមួយចំនួននៅមិនទាន់យល់ច្បាស់អំពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩ នៅឡើយទេ។ ក្នុងន័យនេះ ដើម្បីឱ្យការទូទាត់ប្រាក់បំណាច់អតីតភាពការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងធានាបាននូវសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ក្រសួងសូមបញ្ជាក់សាជាថ្មីជូនម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដូចខាងក្រោម៖

១-ប្រាក់បំណាច់អតីតភាពការងារ ដូចមានចែងក្នុងមាត្រា៨៩ថ្មី នៃច្បាប់ស្តីពីការងារ អនុវត្តចំពោះតែកម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) តែប៉ុណ្ណោះ។

២-ដោយឡែក កម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ដែលមានសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាផង ហើយប្រាក់បំណាច់នេះ មានកំណត់ក្នុងអនុសញ្ញារួម។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើ ៥% នៃប្រាក់ឈ្នួល ដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា។

៣-កម្មករនិយោជិតដែលកំពុងប្រើប្រាស់ប្រភេទកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ដែលលើសថិរវេលាអតិបរមាកំណត់ដោយច្បាប់ ហើយដែលធ្លាប់ទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ (៥%) កន្លងមករួចហើយ គឺមិនអាចសុំឱ្យនិយោជកទូទាត់ប្រាក់រំលឹកបំណាច់អតីតភាពការងារ តាមមាត្រា៨៩ថ្មី នៃច្បាប់ស្តីពីការងារទៀតនោះទេ។

៤-ក្នុងករណីដែលនិយោជកបាននិងកំពុងប្រើប្រាស់កិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) លើសថិរវេលាអតិបរមាកំណត់ដោយច្បាប់ កិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) នោះ ត្រូវប្រែក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) យ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៩ ដោយនិយោជកត្រូវទូទាត់ប្រាក់បំណាច់អតីត


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ភាពការងារ ចាប់ពីកាលបរិច្ឆេទនៃការប្រែក្លាយនោះ ស្របតាមមាត្រា៨៩ថ្មី នៃច្បាប់ស្តីពីការងារ, ប្រកាសលេខ៤៤៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងសេចក្តីណែនាំពាក់ព័ន្ធជាធរមាន។

៥-ប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៩ ត្រូវបានលើកលែងពន្ធ។

៦-កម្មករនិយោជិតមិនទទួលបានប្រាក់បំណាច់អតីតភាពការងារ ក្នុងករណីកម្មករនិយោជិតលាឈប់ដោយឯកឯង ឬបានប្រព្រឹត្តកំហុសធ្ងន់។

ក្រសួងសង្ឃឹមជឿជាក់ថា ការបើកប្រាក់បំណាច់អតីតភាពការងារលើកដំបូងនេះ និងការបើកបន្តបន្ទាប់ទៀត នឹងប្រព្រឹត្តទៅដោយរលូន ដោយរក្សាបានផលប្រយោជន៍ និងស្ថិរភាពការងារជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ក៏ដូចជារក្សាបាននូវភាពវិជ្ជមាននៃទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជាជាក់ជាពុំខាន។ ៤៧

ថ្ងៃ ៨ខ្នូលកើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

-សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ